**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីករណីឆេះរោងម៉ាស៊ីនកិនស្រូវ នៅចំណុចផ្លូវជាតិលេខ៥១ ភូមិតាឡក ឃុំក្បៀមក្សាន្ត ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានទទួលដំណឹងថា មានករណីឆេះរោងម៉ាស៊ីនកិនស្រូវ មូលហេតុដោយសារធ្លាក់កំទេចផ្សារដែក ប៉ះជាមួយកំទេចអង្កាម កាលពីវេលាម៉ោង១៤ និង៣០នាទីរសៀល ថ្ងៃពុធ ១២កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ នៅផ្លូវជាតិលេខ៥១ ភូមិតាឡក ឃុំក្បៀមក្សាន្ត ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ មានកម្មករនិយោជិតសរុប ២៥៦នាក់ (ស្រី២២នាក់) ដែលបណ្តាលឱ្យកម្មករនិយោជិតរងគ្រោះសរុបចំនួន ០៦ នាក់ (ប្រុសទាំងអស់) រងរបួសធ្ងន់ ០៣ នាក់ និង កម្មករនិយោជិតស្លាប់ ០៣នាក់ ។ ជនរងគ្រោះទាំងអស់បានទទួលការជួយសង្គ្រោះ ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច និងមន្រ្តីបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយយកចិត្តទុកដាក់បំផុត។ គិតត្រឹមម៉ោង០៤ និង០០នាទីរសៀល ថ្ងៃព្រហស្បតិ៍ ១៣កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ នេះ កម្មករនិយោជិតចំនួន ០១ នាក់ បាននឹងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត រាជធានីភ្នំពេញ និងកម្មករនិយោជិតចំនួន ០២ នាក់ទៀតបានបន្តទៅព្យាបាលនៅប្រទេសវៀតណាម។ ដោយឡែកកម្មករនិយោជិត ០៣នាក់ ដែលបានស្លាប់ក្នុងគ្រោះថ្នាក់ឆេះរោងម៉ាស៊ីនកិនស្រូវ មន្រ្តីបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចុះសម្របសម្រួលផ្តល់ប្រាក់ឧបត្ថម្ភដល់ក្រុមគ្រួសារនៃជនរងគ្រោះ ដើម្បីរៀបចំពិធីបុណ្យសពតាមប្រពៃណីខ្មែរ និងពិនិត្យមើលលើលទ្ធភាពឧបត្ថម្ភដល់អ្នកនៅក្នុងបន្ទុកនៃជនរងគ្រោះបន្ថែមទៀតផងដែរ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំ និងអាណិតស្រលាញ់ជាទីបំផុត ជាមួយក្រុមគ្រួសារ និងញាតិមិត្តទាំងអស់នៃសព ហើយសូមជូនពរដល់អ្នករងរបួសទាំងអស់ឆាប់បានជាសះស្បើយ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងបន្តជួយដោះស្រាយទុក្ខលំបាករបស់បងប្អូនកម្មករកម្មការិនី និងក្រុមគ្រួសារទៅតាមគោលរបបសន្តិសុខសង្គមរបស់បេឡាជាតិរបបសន្តិសុខសង្គម។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨